# សហគមន៍ខ្មែរកម្ពុជាក្រោម

KHMER KAMPUCHEA KROM COMMUNITY

LA COMMUNAUTÉ DU KHMER KAMPUCHEA KROM


លេខ ០៤១/០៩ ស.ខ.ក.ក.

## គោរពជូន

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

## នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

**កម្មវត្ថុ** : សំណើលើកយកបញ្ហាខ្មែរកម្ពុជាក្រោមជូន ឯកឧត្តម **ណុង ឌឹកម៉ាញ់** អគ្គលេខាធិការបក្សកុម្មុយនិស្តវៀតណាម

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមអនុញ្ញាតជំរាបជូនសម្តេចនាយករដ្ឋមន្ត្រីមេត្តាជ្រាបថា ស្របពេលដំណើរបំពេញទស្សនកិច្ចជាផ្លូវការរបស់ឯកឧត្តម **ណុង ឌឹកម៉ាញ់** អគ្គលេខាធិការបក្សកុម្មុនិស្តវៀតណាម មកកាន់ព្រះរាជាណាចក្រកម្ពុជា ចាប់ពីថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៩ ខាងមុខនេះ ក្នុងនាមតំណាងអង្គការ-សមាគមខ្មែរកម្ពុជាក្រោម ខ្ញុំសូមសម្តេចមេត្តា លើកយកបញ្ហាទុក្ខលំបាករបស់ប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ដែលកំពុងជួបប្រទះយ៉ាងធ្ងន់ធ្ងរនាពេលបច្ចុប្បន្នជូនឯកឧត្តម **ណុង ឌឹកម៉ាញ់** ដើម្បីពិភាក្សា និងដោះស្រាយ ។

***សម្តេចជាទីគោរព !***

បញ្ហាចំពោះមុខ ដែលកំពុងកើតមានចំពោះប្រជារាស្ត្រខ្មែរកម្ពុជាក្រោមមាន :

១_អាជ្ញាធរវៀតណាមបានរឹបអូសយកដីធ្លីពីប្រជារាស្ត្រខ្មែរស្ទើរគ្រប់ទីកន្លែង នៅទូទាំងកម្ពុជាក្រោម (បច្ចុប្បន្ន សាធារណរដ្ឋសង្គមនិយមវៀតណាមប៉ែកខាងត្បូង) ជាពិសេសក្នុងពេលថ្មីៗនេះ ប្រជារាស្ត្រខ្មែរកម្ពុជាក្រោមប្រមាណជាង ៥០គ្រួសារ នៅក្នុងឃុំអាងកី ស្រុកតិនបៀង ខេត្តអានយ៉ាង (មាត់ជ្រូក) ត្រូវបានអាជ្ញាធរវៀតណាមរឹបអូស យកដីធ្លី និងប្រើអំពើហឹង្សាវាយដំ យ៉ាងធ្ងន់ធ្ងរ ដោយពុំមានសំណងអ្វីឡើយ ។

២_អក្សរសាស្ត្រខ្មែរពុំត្រូវបានរដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម អនុញ្ញាតឲ្យសិក្សារៀនសូត្រ ដោយសេរីឡើយ ។

៣_ព្រះសង្ឃពុទ្ធសាសនាខ្មែរ ត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់សមាគមពុទ្ធសាសនាឯកភាពវៀតណាម និងតាមវត្តអារាមនានា ត្រូវបង់វិភាគទានជូនរដ្ឋជាកំហិត ព្រមទាំងបង្ខំឲ្យព្រះសង្ឃធ្វើស្រែចំការចិញ្ចឹមសត្វពាហនៈ ដូចគ្រហស្ថ ។

៤_តាមដាន និងគំរាមកំហែងព្រះសង្ឃ និងប្រជាពលរដ្ឋខ្មែរ មិនឲ្យមានការទំនាក់ទំនងគ្នា ឬជួបប្រជុំ ដើម្បីពិភាក្សា អំពីបញ្ហាសង្គម ឬនយោបាយឡើយ ។

៥_បញ្ចូលសញ្ជាតិខ្មែរ ទៅជាសញ្ជាតិវៀតណាម ដោយមិនបានសួរសាមីខ្លួន ដែលជាប្រជារាស្ត្រខ្មែរ មានសញ្ជាតិជាខ្មែរពីកំណើតនោះឡើយ (រំលាយសញ្ជាតិខ្មែរទៅជាសញ្ជាតិវៀតណាម) ។


ទីស្នាក់ការបណ្តោះអាសន្នផ្ទះលេខ: 10B ផ្លូវលេខ 234 សង្កាត់ទឹកល្អក់ ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: (៨៥៥) ១២ ៩០៨ ៨៨២ / ០៩០ ៩៧៧ ០០៧

E-mail: senthach2000@yahoo.com: Website: http//khmerkromngo.org

សេចក្ដីដូចបានជំរាបជូនខាងលើ សូមសម្ដេចមេត្តាជ្រាប និងលើកយកបញ្ហាទាំងនោះ ជូនឯកឧត្តម **ឈាង ឌឹកម៉ាញ់** ក្នុងឱកាសដែលសម្ដេចអនុញ្ញាតឲ្យឯកឧត្តម **ឈាង ឌឹកម៉ាញ់** ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ដើម្បីដោះស្រាយជូនប្រជារាស្ត្រខ្មែរកម្ពុជាក្រោម ដែលកំពុងរងគ្រោះ នាពេលបច្ចុប្បន្ន ដោយអនុគ្រោះ ។

សូមសម្ដេចប្រធាន មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំ ។

*រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៩៨*

**នាយកប្រតិបត្តិសហគមន៍ខ្មែរកម្ពុជាក្រោម**

**ថាច់ សេដ្ឋា**

**សមាជិកក្រុមប្រឹក្សារាជធានីភ្នំពេញ**

**និងជាអតីតសមាជិកព្រឹទ្ធសភា**